ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក
ស
វ

# Work Activities

ប្រចាំខែមីនា ឆ្នាំ២០១៨



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចទេសចរណ៍ | ១-២ |
| ២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរ័ណនិងល្បែងពាណិជ្ជកម្ម | ៣-៤ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត(ក្រុម RIA) | |
| - វគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈ លើផែនការយុទ្ធសាស្ត្រ អភិបាលកិច្ចល្អ និងការគ្រប់គ្រងធនធានមនុស្សក្នុងផ្នែកសាធារណៈ | ៥-៧ |
| III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១៨ | ៨-១៥ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៨ | ១៦-១៩ |

# ១- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចទេសចរណ៍

កាលពីថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃ២០ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍** ដោយមានការ អញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងទេសចរណ៍។

ដោយផ្អែកលើគោលនយោបាយជាយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងការដឹកនាំដោយផ្ទាល់របស់ ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ វិស័យទេសចរណ៍កម្ពុជាត្រូវបានទទួលស្គាល់ និងមានភាពល្បីល្បាញនៅលើឆាកអន្តរជាតិ ហើយបានទាក់ទាញភ្ញៀវអន្តរជាតិឲ្យមានទស្សនាកំសាន្ត និងវិនិយោគនៅកម្ពុជាកាន់តែច្រើនឡើងៗ។ ទន្ទឹមនឹងកំណើនភ្ញៀវទេសចរនេះ យើងសង្កេតឃើញថា មូលដ្ឋានអាជីវកម្មទេសចរណ៍គ្រប់ប្រភេទ ក៏មានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់ នៅតាមគោលដៅទាក់ទាញទេសចរណ៍ទូទាំងប្រទេស ដើម្បីឆ្លើយតបភ្លាមៗទៅនឹងតម្រូវការរបស់ភ្ញៀវ។

កន្លងមក យោងតាមមាត្រា៥៦ នៃច្បាប់ស្តីពីទេសចរណ៍ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ឆ្នាំ២០១៦ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ អង្គភាពអធិការកិច្ចនៃក្រសួងទេសចរណ៍ត្រូវបានកែសម្រួលរចនាសម្ព័ន្ធថ្មីទៅជាអគ្គាធិការដ្ឋាននៃក្រសួងទេសចរណ៍។

ក្រោយពីទទួលគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍ រួចមកអគ្គាធិការដ្ឋានទេសចរណ៍បានរៀបចំសេចក្តីព្រាងនៃការកែសម្រួលអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ ដើម្បីឲ្យសមស្របតាមរចនាសម្ព័ន្ធថ្មីរបស់ក្រសួងទេសចរណ៍។ សេចក្តីព្រាងនៃការកែសម្រួលនេះ ត្រូវបានរៀបចំឡើងតាមទម្រង់ និងបទដ្ឋានបច្ចេកទេសត្រឹមត្រូវ ដោយ

អនុក្រឹត្យថ្មីនេះ មានខ្លឹមសារក៏មិនខុសពីអនុក្រឹត្យចាស់គឺគ្រាន់តែបន្ថែមឯកសណ្ឋាន សញ្ញាសម្គាល់ និង សញ្ញាសក្តិ សម្រាប់ថ្នាក់អគ្គធិការ និងអគ្គាធិការរងប៉ុណ្ណោះ[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លង កិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចទេសចរណ៍។

# ២-សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការគ្រប់គ្រងរមណីយដ្ឋានសមាហរណៈ និងល្បែងពាណិជ្ជកម្ម

កាលពីថ្ងៃព្រហស្បតិ៍ ៦កើត និងថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃ ២២ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណៈនិងល្បែងពាណិជ្ជកម្ម** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់វិស័យទេសចរណ៍ និងបង្កើតការងារតាមរយៈការកំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រង ការប្រមូលចំណូល និងរក្សាសុវត្ថិភាព និងសន្តិសុខសង្គមពាក់ព័ន្ធនឹងល្បែងពាណិជ្ជកម្ម ព្រមទាំងការផ្តល់សិទ្ធិដល់នីតិបុគ្គល និងរូបវន្តបុគ្គល ក្នុងការធ្វើប្រតិបត្តិការដោយផ្ទាល់ ឬចូលរួមនៅក្នុងល្បែងពាណិជ្ជកម្មកាស៊ីណូ ល្បែងអនឡាញ និងល្បែងពាណិជ្ជកម្មដទៃទៀត ឬធ្វើជាម្ចាស់កម្មសិទ្ធិលើគ្រឹះស្ថាន នៃទីតាំងប្រតិបត្តិការនោះ រួមទាំងការអភិវឌ្ឍ "រមណីដ្ឋានសមាហរណៈ"។

ការបង្កើតច្បាប់នេះ ក្នុងគោលដៅធានា ល្បែងពាណិជ្ជកម្មកាស៊ីណូ ល្បែងអនឡាញ និងល្បែងពាណិជ្ជកម្មដទៃទៀតក្រៅពីកាស៊ីណូ ការអភិវឌ្ឍ និងកម្មសិទ្ធិលើគ្រឹះស្ថានដែលជាទីតាំងនៃប្រតិបត្តិការនោះ៖

- ប្រព្រឹត្តទៅដោយយុត្តិធម៌ ជឿទុកចិត្តបាន និងមិនស្ថិតនៅក្រោមឥទ្ធិពលនៃបទល្មើសព្រហ្មទណ្ឌ
- ត្រូវបានអនុវត្តដោយនីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានគុណវុឌ្ឍិ
- ត្រូវបានការពារពីការក្លែងបន្លំ និងការឆបោក
- បង្កើតប្រភពចំណូលសម្រាប់ប្រទេសកម្ពុជា
- បង្កើតដោយផ្ទាល់ឬដោយប្រយោលនូវការងារ ជំរុញលំហូរចូលនៃភ្ញៀវទេសចរ អភិវឌ្ឍសេដ្ឋកិច្ច រួមចំណែកក្នុងសុខដុមនីយកម្មសង្គមនិងលើកកម្ពស់កិត្តិនាមរបស់ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសគោលដៅកម្សាន្តអន្តរជាតិ
- ប្រព្រឹត្តទៅដោយមានការទប់ស្កាត់ការចូលលេងល្បែងរបស់អ្នកដែលត្រូវហាមឃាត់ និងកាត់បន្ថយជាអតិបរមានូវការប៉ះពាល់អវិជ្ជមានពីការលេងល្បែងចំពោះសង្គម

- គោរពតាមស្តង់ដាជាធរមាននៃវិស័យនេះចំពោះ“រមណីយដ្ឋានសមាហរណ” កម្រិតអន្តរជាតិ និង ស្តង់ដាសម្រាប់វិស័យកាស៊ីណូនៅលើទិដ្ឋភាពនៃប្រតិបត្តិការគណនេយ្យហិរញ្ញវត្ថុនិងអនុលោមភាព។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

# វគ្គបណ្តុះបណ្តាលស្តីពី
# គោលនយោបាយសាធារណៈលើផែនការយុទ្ធសាស្រ្ត អភិបាលកិច្ចល្អ និងការគ្រប់គ្រងធនធានមនុស្ស ក្នុងផ្នែកសាធារណៈ
## នៅសាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ



នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្រ្តី បានសហការជាមួយសាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ ៨៨៣៤ សម្រាប់ កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) បានបើកវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈលើផែនការយុទ្ធសាស្រ្ត អភិបាលកិច្ចល្អ និងការគ្រប់គ្រងធនធានមនុស្សក្នុងផ្នែកសាធារណៈ ដល់មន្រ្តីក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ក្រុមការងារRIA) ចំនួន ៣៥នាក់




មកពី ១៩ក្រសួង-ស្ថាប័ន៖ (ECOSOCC ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងរ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។





ការបើកវគ្គបណ្តុះបណ្តាលនេះក្រោមអធិបតីភាពឯកឧត្តម **ឃឹម ណុលសន** អនុប្រធាន ECOSOCC និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ហើយវាគ្មិនសុទ្ធតែអ្នកដែលមានបទពិសោធន៍ខ្ពស់រួមមាន **Mr. Raymond Leos** ជាជនជាតិអាមេរិចដែលបានបម្រើការជាអ្នកពិគ្រោះយោបល់នាំមុខ សម្រាប់គម្រោងថ្នាក់ជាតិនិងអង្គការជាច្រើននៅក្នុងប្រទេសកម្ពុជារួមទាំង រដ្ឋសភា ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និង UNESCO ។ **Dr. Peter Chandra** ជាជនជាតិអូស្ត្រាលីដែលជាអ្នកប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រនិងភាពជាអ្នកដឹកនាំ ដែលបានបម្រើការនៅអាស៊ីជាង ២០ឆ្នាំមកហើយ។ **Dr. Peter Chandra** បានបម្រើការងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ដូចជា នាយកប្រតិបត្តិ នាយក និងជាប្រធាននៅក្នុងអង្គការជាច្រើនរួមមានក្រុមហ៊ុនសាធារណៈដែលបានចុះបញ្ជី អង្គការក្រៅរដ្ឋាភិបាល និងសហគ្រាសធុនតូចនិងមធ្យម។ **Dr. Fermin Diez** មានសញ្ជាតិអាមេរិកដែលមានជំនាញផ្នែកធនធានមនុស្សជាង ៣៥ឆ្នាំមកហើយ បានបម្រើការងារជាច្រើនរួមមាន អ្នកពិគ្រោះយោបល់ សាស្ត្រាចារ្យ ប្រធានផ្នែកបុគ្គលិកប្រចាំតំបន់ អ្នកនិពន្ធ និងបច្ចុប្បន្នជាអគ្គនាយករងនៃក្រុមប្រឹក្សាជាតិ សង្គមកិច្ច នៅប្រទេសសិង្ហបុរី។

កម្មវិធីពិសេសនេះបង្កើតឡើងសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ដែលបម្រើការងារនៅផ្នែកសាធារណៈ និងមានភារកិច្ចចូលរួមផ្ទាល់លើការងារអភិវឌ្ឍន៍គោលនយោបាយសាធារណៈ។ វគ្គសិក្សាក្នុងរយៈពេល ៥ថ្ងៃនេះផ្តោតសំខាន់លើ៣ផ្នែកគឺ ផែនការយុទ្ធសាស្ត្រ អភិបាលកិច្ចល្អ និងការគ្រប់គ្រងធនធានមនុស្ស។ កម្មវិធីនេះផ្តល់ឱ្យសិក្ខាកាមនូវក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ ដែលអាចយកទៅអនុវត្តតាមក្រសួងស្ថាប័នរៀងខ្លួនៗ។ កម្មវិធីមានភាពរហ័សរហួននិងអន្តរសកម្មខ្ពស់នេះនឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើគណនេយ្យភាពសាធារណៈនិងតម្លាភាព ហើយយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់ការធ្វើផែនការរយៈពេលវែង ព្រមទាំងរបៀបដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យសាធារណៈ។

# III- កិច្ចប្រជុំស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្ដម **យឹម ណុលសុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែកុម្ភៈឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៤% ធៀបនឹងខែមុន និងកើនឡើង២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៦,៩% | ប្រេងសាំង: | +៦,៧% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៣% | ត្រីស្រស់: | +៤,៤% |
| ការដឹកជញ្ជូន: | +២,៩% | សាច់គោ: | +២,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | +១,៧% | សាច់មាន់: | +០,៥% |
| សុខាភិបាល: | +១,៤% | សាច់ជ្រូក: | +០,៣% |
| សំលៀកបំពាក់ និងស្បែកជើង: | +១,២% | | |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +០,៦% | | |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៥% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា P | មេសា P | ឧសភា P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២% | ២,៣% | ២,៥% | ២,៣% | ២,៨% | | | | | | | | |
| | មុន | ០,១% | ០,៤% | ០,២% | ០,៣% | ០,៣% | | | | | | | | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

P: តួលេខខែមីនា មេសា និងឧសភា ឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តារាង




១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កុម្ភៈ ២០១៨ | មករា ២០១៨ | កុម្ភៈ ២០១៧ | *ប្រភេទ* | កុម្ភៈ ២០១៨ | មករា ២០១៨ | កុម្ភៈ ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០១០៛/១$ | ៤០១៥៛/១$ | ៤០០៤៛/១$ | **បាត/ដុល្លារ** | ៣១,៤៥បាត/១$ | ៣១,៤១បាត/១$ | ៣៤,៨៥បាត/១$ |
| **៛/បាត** | ១២៨៛/១បាត | ១២៨៛/១បាត | ១១៥៛/១បាត | **ដុង/ដុល្លារ** | ២២៧២៧ដុង/១$ | ២២៦៩៥ដុង/១$ | ២២៧៧៧ដុង/១$ |
| **៛/ដុង** | ០,១៧៦៛/១ដុង | ០,១៧៧៛/១ដុង | ០,១៧៦៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកុម្ភៈ ឆ្នាំ ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៣២៨,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៣២,២ លានដុល្លារ ( *មធ្យមប្រចាំខែ ៨៧% នៃផែនការ*) ក្នុងនោះ ចំណូលចរន្តចំនួន១៣២៨,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៣២,២ លានដុល្លារ ( *មធ្យមប្រចាំខែ ៨៩% នៃផែនការ*) និងមិនមានចំណូលមូលធនទេ (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង ៥,៥% ប៉ុន្តែ ថយចុះ៦,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១១៨១,៥ប៊ីលានរៀល កើនឡើង៤,៩%ធៀបនឹងខែមុនប៉ុន្តែថយចុះ៩,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៤៧,៣ប៊ីលានរៀល កើនឡើង២២,១%ធៀបនឹងខែមុន និងកើនឡើង២៨,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ<br>(ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៣,៥%<br>(អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+២០,១%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +៦១,៦% | (-០,៩%) |
| | | ➢ នេសាទ:-៩៣,៦% | (-៥៩,៦%) |
| ➢ ចំណូលពន្ធដារ: -៣%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (-៤១%) | ➢សម្បទានរ៉ែ: -៣៣,៩% | (+៣៥២,៥%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: កើនឡើងគំហុគ | (+២១,១%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -០,៨% | (+៥០,៤%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១១៣០,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៨២,៥ លានដុល្លារ (*មធ្យមប្រចាំខែ ៥៩% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១០២១ប៊ីលានរៀល (*មធ្យមប្រចាំខែ ៦៨% នៃផែនការ*) និងចំណាយមូលធនមានចំនួន១០៩,៤ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង៥៥,៨%ធៀបនឹងខែមុននិងកើនឡើង២៧,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៤៣,៥%ធៀបនឹងខែមុននិងកើនឡើង២០,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ១៩៨,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៩,៦ លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៧៣១៧៥ប៊ីលានរៀល កើនឡើង១,៣%ធៀបនឹងខែមុន និងកើនឡើង២២,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ០,៣% ប្រាក់បញ្ញើចរន្ត២,១% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ២,៣% និង ប្រាក់បញ្ញើជារូបិយបណ្ណ១,៤%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកុម្ភៈឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៨

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៧% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកុម្ភៈ២០១៨: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៧៨៨លានដុល្លារ ថយចុះ០,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៦,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៦៦៣០ ប៊ីលានរៀលកើនឡើង០,៧% ធៀបនឹងខែមុន និងកើនឡើង២៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កុម្ភៈ២០១៨* | *មករា២០១៧* | *កុម្ភៈ២០១៧* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៦៩៣៥៧ | ៦៨៤២០ | ៥៨២៤៤ |
| ក្នុងនោះ: ជារៀល | | ១៣៨៣ | ៩៤៨ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៧៦២១ | ១៣២៥២ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៥% | ៥,៨៩% | ៦,៨០% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,២៤% | ១២,២៩% | ១៦,២០% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | ៤,៣៨% | ៤,៤៤% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦៥% | ១១,៤៩% | ១១,៦៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៨% | ១៨% | ២៣,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៧% | ១៦,៩% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

- **កសិកម្ម**:
  - ✓នេសាទសម្រេចបាន៥០,៣២ពាន់តោន ថយចុះ៤% ធៀបនឹងខែមុន និងថយចុះ០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៦៨១,១៥GWHមានការថយចុះ១,៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន១៣០,៨៩GWH មានការថយចុះ០,១% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង២២០%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៦៨,៦១GWHមានការថយចុះ០,០០៤% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៧៨,១លានដុល្លារមានការថយចុះ៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន –កុម្ភៈ២០១៨* | *ចំនួន–មករា២០១៨* | *ចំនួន–កុម្ភៈ២០១៧* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៦ | ៧ | ៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៤៥ | ១៥២៩ | ១៥៨៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១២ | ១៩ | ២១ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២៥ | ៤៦ | ៣៤ |

➢ **សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៣៧,៥ពាន់ម៉²ថយចុះ៨០%ធៀបនឹងខែមុន និងថយចុះ៨៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៦៦,៩លានដុល្លារថយចុះ៧៨%ធៀបនឹងខែមុន និង ថយចុះ៨៨%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម៉² –កុម្ភៈ២០១៨* | *ពាន់ម៉² –មករា២០១៧* | *ពាន់ម៉² –កុម្ភៈ២០១៨* |
|---|---|---|---|
| ▪ លំនៅឋាន | ៧៩,៦ | ៣៨៦,៩ | ៤៩៤,៤ |
| ▪ ឧស្សាហកម្ម | ១០,៥ | ៨៤,៨ | ២០៨,៨ |
| ▪ពាណិជ្ជកម្ម | ៣១,៣ | ១៨០,២ | ១៧,២ |
| ▪ ទេសចរណ៍ | ១៥,៥ | ៣៣,៦ | ៩៦,៩ |
| ▪ផ្សេងៗ | ០,១ | ៥,៥ | ០,០ |
| អនុញ្ញាតសរុប | ១៣៧,៥ | ៦៩៤,២ | ៨១៧,៨ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៥៧,៨% និងពាណិជ្ជកម្ម២២,៧%នៃផ្ទៃក្រឡាសរុប។

➢ **ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| *ប្រភេទ* | *នាក់–កុម្ភៈ ២០១៨* | *នាក់–មករា ២០១៨* | *នាក់–កុម្ភៈ ២០១៧* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ១៥៥២ | ១០៦៧ | ២២៩៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៥៧៣៥ | ១៥១៨៨ | ១២០០៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១១០២១ | ១០៨៩១ | ៩៣៣១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៧១៤ | ៤២៩៧ | ២៦៧២ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កុម្ភៈ២០១៨ | មករា២០១៨ | កុម្ភៈ២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១១៩,២ | ២០៧,៩ | ៤១៩,៦ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៣,៣ | ២,២ | ៧០,២ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៧៥,៩ (៧) | ១៧២,៦ (១២៨) | ៣៤៩,៥ (២៦២,៦) |
| វិស័យទេសចរណ៍ | ០,០ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ៣៣ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៤ | ២៥ | ១៨ |
| បង្កើតការងារ (ពាន់នាក់) | ១១ | ១០ | ២៨,២ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—កុម្ភៈ២០១៨ | ចំនួន—មករា២០១៨ | ចំនួន—កុម្ភៈ២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១០៨៤ | ៨២២ | ៤១៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១០ | ៩ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធជារតាមរបបពិត | | | ៦១៦ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន១៣០៥,៨ពាន់តោនកើនឡើង២១% ធៀបនឹងខែមុន និងកើនឡើង៩៣%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងរង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+១៤៩% | (+២៤៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+០,៤% | (+៣៧៤%) |
| ▪ កំពង់ផែកំពង់សោម:-៣២% | (+២៤%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +២៧១% | (+៥៩%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៩.៦ | -៤% | ២៧% |
| ក្នុងនោះទទួល | ២,២ | -១៥% | -៥% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១១៦,៣ | -៧% | ៣% |
| ក្នុងនោះទទួល | ៥៥,៦ | -១០% | ២០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៨៨០,៧ | -១៣% | -២១% |
| ក្នុងនោះហៅចូល | ៥៥៤,៩ | -១១% | -២០% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៦០៣៥,៧ | ២% | -៤៤% |
| ក្នុងនោះហៅចូល | ៥៩៦១,៧ | ២% | -៤៤% |

### ➤ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៨,៣ | ១៥% | -១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៧៨,៦ | ២១% | ៦៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៨៦៨,៤ | 0% | ២៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៤២,៣ | -៣,១% | ១៧% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៥៤២,៩ | -៩% | ១០% |
| ✓ តាមផ្លូវអាកាស | ៣៧៤ | -៤% | ២៤% |
| ✓ តាមផ្លូវគោក និងទឹក | ១៦៩ | -១៩% | -១២% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកុម្ភៈ ឆ្នាំ២០១៨ មានចំនួន ៤៩៧៧ប៊ីលានរៀល (ស្មើនឹង ១២៤៤លានដុល្លារ ស.រ.អា.)កើនឡើង៣,៧%ធៀបនឹងខែមុន និងកើនឡើង១៧,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១៣,៨% | +១៤,៣% | រថយន្តសរុប (ប៊ី.ល.រ) | -៧,៧% | +១៩,៤% |
| ប្រេងម៉ាស៊ូត | +១៣,៧% | -៧,៧% | រថយន្តសរុប (គ្រឿង) | -៩,៥% | -៤,៧% |
| ឧស្ម័ន | -២៥,៦% | -១,៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +២៥,៣% | +៣១,៩% |
| អគ្គិសនីនាំចូល | -៨% | +៦% | ម៉ូតូ (គ្រឿង) | +៣,៣% | +២៣,២% |
| ដែកសំណង់ | -១,៨% | +៦៥,៥% | អង្ករ | -៣៩,៤% | +១០៥,៤% |
| ស៊ីម៉ង់ត៍ | -១៤,៣% | -៧,៦% | ផ្លែឈើនិងបន្លែ | -១៦% | +១៧,៣% |
| គ្រឿងអេឡិចត្រូនិក | +៣៨,៩% | +៣៤០,៧% | ជីនិងថ្នាំកសិកម្ម | -៤,៧% | -១៣,៧% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១៧,៩% | +៦៨% |

➡ **ការនាំចេញ** ខែកុម្ភៈឆ្នាំ២០១៨ មានចំនួន**៣៥៤៩,៨**ប៊ីលានរៀល ស្មើនឹង**៨៨៧,៥**លានដុល្លារ ស.រ.អា. (**៧១**% នៃការនាំចូល)ថយចុះ៦,២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៦,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៥៥,៣% | +៤១៣% | ផលិតផលនេសាទ | +៦៣,៤% | +៤00,២% |
| វាយនភណ្ឌនិងស្បែកជើង | +៥,៩% | +១២,៨% | កៅស៊ូ | -៥៤,៣% | -២0,៣% |
| អង្ករ | -២៧,៥% | -២0,៩% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃត្រីស្រស់ | ០,៣% | ៤,៤% | |
| ២ | ចំណូលពន្ធដារ | -៣,០% | -៤១,០% | ពីនាយកដ្ឋានពន្ធដារផ្ទាល់ |
| ៣ | ពន្ធលើប្រាក់ចំណេញ | -៣៤,៤% | -៤១,០% | |
| ៤ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | -៣៧,០% | -៤៣,០% | |
| ៥ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | -៤៦,០% | -២៦,០% | |
| ៦ | សំណង់អនុញ្ញាតឲ្យសាងសង់ (គិតជាផ្ទៃក្រឡា) | -៨០,០% | -៨៣,០% | |
| ៧ | សំណង់អនុញ្ញាតឲ្យសាងសង់(គិតជាសាច់ប្រាក់) | -៧៨,០% | -៨៨,០% | |

## ៧) សេចក្តីសន្និដ្ឋាន

១) បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ នាដើមឆ្នាំ២០១៨ មានកម្រិតទាប (ខែកុម្ភៈ ២០១៨ មានកំណើន ២,៣% ធៀបនឹងខែដូចគ្នា ឆ្នាំ២០១៧) និងរំពឹងថាថ្លៃទំនិញនឹងមិនមានការប្រែប្រួលខ្លាំងក្នុងឆ្នាំ២០១៨នេះទេ។ លទ្ធផលនេះ ជារួមបណ្តាលមកពីគោលនយោបាយរក្សាស្ថេរភាពថ្លៃ។

២) ដោយឡែក ថ្លៃឥន្ធនៈ អាចនឹងកើនឡើងខ្ពស់ក្នុងអំឡុងឆ្នាំ ២០១៨ ព្រោះថាថ្លៃឥន្ធនៈពឹងផ្អែកខ្លាំងលើថ្លៃសាកលលោកដែលកំពុងមាននិន្នាការកើនឡើង។

៣) តួលេខទុនបម្រុងជារូបិយបណ្ណបរទេសបានធ្លាក់ចុះចំនួនប្រហែល២២លានដុល្លារក្នុងខែកុម្ភៈនេះ ដោយសារថ្លៃមាសធ្លាក់ចុះ និងការធ្លាក់ចុះថ្លៃរូបិយបណ្ណផ្សេងទៀតដែលជាសមាសភាពទុនបម្រុងធៀបនឹងប្រាក់ដុល្លារអាមេរិក។

៤) មានការលើកឡើងថា ឥណទាននឹងមានកំណើនទាបក្នុងឆ្នាំ២០១៨ រីឯតួលេខអនុញ្ញាតិក្នុងវិស័យសំណង់ និងវិនិយោគ ក៏មានការធ្លាក់ចុះមួយកម្រិត៕

## IV- សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៣/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយសមាជិកសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |
| ២ | ០៥/០៣/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធឧបដ្ឋានសាលា និងសមិទ្ធផលនានាក្នុងវត្តឈូកវ៉ា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវត្តឈូកវ៉ា ភូមិអណ្តូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ |
| ៣ | ០៦/០៣/១៨ ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការជាស្ត្រីក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១០៧ និងពិធីប្រកាសជាផ្លូវការដាក់ឲ្យអនុវត្តន៍ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៧/០៣/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់ក្រុងតាខ្មៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅកីឡាដ្ឋានខេត្តកណ្តាល ក្រុងតាខ្មៅ ខេត្តកណ្តាល។ |
| ៥ | ០៨/០៣/១៨ ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី១០៧ ទិវាអន្តរជាតិនារី ៨ មីនា ២០១៨ ក្រោមប្រធានបទ“ស្ត្រីរួមគ្នារក្សាសន្តិភាពដើម្បីអភិវឌ្ឍជាតិ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ៦ | ១០/០៣/១៨ ម៉ោង០៨:០០នាទី | ចូលរួមប្រជុំពិភាក្សាអំពីការផ្ទៀងផ្ទាត់បញ្ជីបេក្ខជនតំណាងរាស្ត្រ នីតិកាលទី៦ របស់មណ្ឌលខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | **១០/០៣/១៨ ម៉ោង១៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកជាផ្លូវការពិធីបុណ្យទន្លេលើកទី៤ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅក្រុងតាខ្មៅ ខេត្តកណ្តាល។ |
| ៨ | **១២/០៣/១៨ ម៉ោង០៧:៤៥នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍ការងារឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ |
| ៩ | **១៣/០៣/១៨ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ កំណាត់ផ្លូវប្រវែង ៤គីឡូម៉ែត្រ ដំណាក់កាលទី៤ នៃគម្រោងធ្វើឲ្យប្រសើរឡើងវិញផ្លូវជាតិលេខ១ ពីគីឡូម៉ែត្រលេខ០+០០០ គល់ស្ពានព្រះមុនីវង្ស ដល់គីឡូម៉ែត្រលេខ៤+០០០ ក្រោមជំនួយឥតសំណងពីរដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ |
| ១០ | **១៤/០៣/១៨ ម៉ោង១១:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុខដានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **១៥/០៣/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៨ លើប្រធានបទ "វិទ្យាសាស្រ្ត និងបច្ចេកវិទ្យាសម្រាប់ឧស្សាហូបនីយកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ១២ | **១៩/០៣/១៨ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | ២១/០៣/១៨<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់ភូមិជ្រៃកោង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ១៤ | ២១/០៣/១៨<br>ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ១៥ | ២២/០៣/១៨<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតអធិការអប់រំជំនាន់ទី២ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផែនគ្រប់គ្រងអប់រំជំនាន់ទី៤ គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី២២ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាជំនាន់ទី១ នៃវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៦ | ២២/០៣/១៨<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៣/០៣/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១១ និងផ្លូវវាង ប្រវែងសរុប៩៦.៤៨គ.ម ចាប់ពីអ្នកលឿងចំណុចប្រសព្វផ្លូវជាតិលេខ១ ខេត្តព្រៃវែង ដល់ថ្នល់ទទឹងចំណុចប្រសព្វផ្លូវជាតិលេខ៧ ខេត្តត្បូងឃ្មុំ ក្រោមហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រែកឈ្លៀង ឃុំព្រែកឈ្លៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ |
| ១៨ | ២៤/០៣/១៨<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គ្រូពេទ្យ មន្ត្រីរដ្ឋបាលស្រុក និងប្រធានក្រុមប្រឹក្សាឃុំ ទូទាំងស្រុកកោះអណ្តែត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ស្រុកកោះអណ្តែត ខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៩ | ២៧/០៣/១៨<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតសាកលវិទ្យាល័យ អាស៊ីអឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២០ | ២៧/០៣/១៨<br>**ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលប្រចាំឆ្នាំ ២០១៧ លើកទី៣៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ២១ | ២៨/០៣/១៨<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់ព្រៃទា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិក្បាលដំរី២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ២២ | ២៩/០៣/១៨<br>**ម៉ោង០៧:៤៥នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងាររយៈពេល០៥ឆ្នាំ និងទិសដៅការងាររបស់វិស័យមុខងារសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ២៣ | ៣០/០៣/១៨<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in